ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៦១/១១-ខេមប្រ៊ូវ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **យូ សួនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **អាំង អេងថុង**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ស្រាបៀរ កម្ពុជា ខេមប្រ៊ូវ**

អាសយដ្ឋាន : អាគារលេខ២១៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨១៣ ៣៨៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

- លោក សារិន ដេណូវ៉ា មេធាវី

២- ភាគីកម្មករនិយោជិត

ឈ្មោះ : **- សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (សកចសក)**

**- សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុនផលិតស្រាបៀរអង្គរ**

អាសយដ្ឋាន : ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល

លេខទូរស័ព្ទ : ០១៧ ៤៧៣ ៤៨២ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ទុយ ស៊ីធៀង មន្ត្រីវិវាទនៃ ស.ក.ច.ស.ក

២- កញ្ញា ទេព ផល្លីន មន្ត្រីវិវាទនៃ ស.ក.ច.ស.ក

៣- លោកស្រី ស៊ឹម ចាន់ធឿន ប្រធានសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុនផលិតស្រាបៀរអង្គរ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់សំណងបន្ថែម១០០ ភាគរយ សម្រាប់កម្មករនិយោជិត ដែលធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំថ្ងៃ គិតចាប់ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១០ ព្រោះកាលនោះ ក្រុមហ៊ុនបានផ្តល់ឱ្យតែចំនួន ២ ដុល្លារប៉ុណ្ណោះ សម្រាប់កម្មករដែលបានធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍របស់ខ្លួន (សុំឱ្យក្រុមហ៊ុនអនុវត្តតាមច្បាប់ស្តីពីការងារ ត្រង់មាត្រា ១៣៩ និងមាត្រា ១១៨)។

២- ស្នើឱ្យក្រុមហ៊ុនអនុវត្តកិច្ចសន្យាការងារគ្មានថិរវេលាកំណត់ ចំពោះកម្មករនិយោជិតដែលធ្វើការចាប់ពី ២ ឆ្នាំឡើងទៅ។

ដោយឡែកភាគីខាងក្រុមហ៊ុនអវត្តមានក្នុងថ្ងៃផ្សះផ្សា ដោយពុំបានបញ្ជាក់ពីមូលហេតុច្បាស់លាស់ឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៥៤៧ ក.ប/អក/វ.ក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ ។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ( វេលាម៉ោង ០៨:៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងរបស់សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា លេខ ០១៧/១១ សកចសក ស្តីពីការទាមទារសុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានកាន់តែល្អប្រសើរឡើង។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីធ្វើការផ្សះផ្សាវិវាទការងារនេះ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០២ ចំណុច លើការទាមទារចំនួន ០២ ចំណុច។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ តាមរយៈរបាយការណ៍មិនសះជាលេខ ៦៤៧ កប/អក/វក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំរោងចក្រមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក ប៉ុន្តែ ពុំមានចំណុចវិវាទណាមួយទទួលបានការសះជានឹងគ្នាទេ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេច ដូចខាងក្រោម :

**ឥស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ឥស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតរបស់ក្រុមហ៊ុន ស្រាបៀរកម្ពុជា ខេមប្រ៊ូវ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើរសុំលើកពេលសវនាករ លេខ ៦១/១១ កសអ ចុះថ្ងៃ០៦ ខែមិថុនា ឆ្នាំ ២០១១។

២- ស្នាមមេដៃរបស់បុគ្គលិកក្រុមហ៊ុន ខេមប្រ៊ូវ ចំនួន ១៦ នាក់ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១ ដែលបានបដិសេធមិនទទួលស្គាល់លើការផ្តិតមេដៃនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ លើលិខិតលេខ ១៤១២/១០ សកចសក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ ដែលមានចំនួន៥ចំណុច។

៣- លិខិតលេខ ៦៦/១១ កសអ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការផ្ទេរសិទ្ធិជូនលោកបណ្ឌិត សារិន ដេល្វ៉ា ដើម្បីចូលរួមដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

៤- កិច្ចព្រមព្រៀង( នារីជំនួយការលក់) របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ ស៊ឹម ផល្លា អត្តលេខ C ០៤៨៤ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩។

៥- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ស្រាបៀរ កម្ពុជា ខេមប្រ៊ូវ លេខ ២៩៩៣ ពណ.ចបព ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨។

៦- លក្ខន្តិកៈរបស់ក្រុមហ៊ុន ស្រាបៀរ កម្ពុជា ខេមប្រ៊ូវ តំកល់ទុកនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម លេខ ៩៨១/០២ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២។

៧- បញ្ជីឈ្មោះបុគ្គលិកក្រុមហ៊ុន ខេមប្រ៊ូវ ចំនួន ៣៤៧ នាក់ ដែលបានផ្តិតមេដៃ ដើម្បីឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលរបស់ខ្លួនចំនួន ១០០០ រៀល បង់ភាគទានឱ្យសហជីពបុគ្គលិកកម្មករជឿនលឿននៃក្រុមហ៊ុន ស្រាបៀរអង្គរ។

៨- កិច្ចព្រមព្រៀង(នារីជំនួយការលក់)របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ ស ស្រីអូន អត្តលេខ FC ០០៩៩, ថុន សុភា អត្តលេខ FC ០០០៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០។

៩- កិច្ចព្រមព្រៀង(នារីជំនួយការលក់)របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ ញឹម ណារិន អត្តលេខ FC ០២៣៨ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០។

១០- កិច្ចព្រមព្រៀង(នារីជំនួយការលក់)របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ យឹម សំអឿន អត្តលេខ FC ០២៥៤ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១០។

១១- កិច្ចព្រមព្រៀង(នារីជំនួយការលក់)របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ ហែម សុគន្ធា អត្តលេខ FC ០៣១១ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១០។

១២- កិច្ចព្រមព្រៀង(នារីជំនួយការលក់)របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ ឡុង រតនៈ អត្តលេខ C ០០៦១ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨។

១៣- កិច្ចព្រមព្រៀង(នារីជំនួយការលក់)របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ សំណាង ដាលីន អត្តលេខ FC ០០១០។

១៤- កិច្ចព្រមព្រៀង(នារីជំនួយការលក់)របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ ឈុន ឡាយលីន អត្តលេខ C ០២១០ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨។

១៥- កិច្ចព្រមព្រៀង(នារីជំនួយការលក់)របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ នាង ថន អត្តលេខ FC ០០៦០ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨។

១៦- កិច្ចព្រមព្រៀង(នារីជំនួយការលក់)របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ ដាំ ចំរុង ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- កិច្ចព្រមព្រៀង(នារីជំនួយការលក់)របស់ក្រុមហ៊ុន ខេមប្រ៊ូវ និងឈ្មោះ ដាំ ចំរុង អត្តលេខ ជ ០៥៣៤ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០។

២- ស្នាមមេដៃរបស់បុគ្គលិករបស់ក្រុមហ៊ុន ខេមប្រ៊ូវ ចំនួន ៣៨ នាក់ ដែលបដិសេធលើការផ្តិតមេដៃឱ្យក្រុមហ៊ុនកន្លងមក ហើយសូមរក្សាជំហរទាមទារលើបញ្ហាចំនួន៣ចំណុច( ៣ក់ព័ន្ធប្រាក់ឈ្នួល ២០០% ពេលធ្វើការបែមម៉ោងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍. ទាមទារប្រាក់សំណង១០០%ដែលក្រុមហ៊ុនទូទាត់មិនបានត្រឹមត្រូវនៅពេលធ្វើការបែមម៉ោងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍. ទាមទារប្តូរកិច្ចសន្យាការងារទៅកិច្ចសន្យាមិនកំណត់ថិរវេលានៅពេលធ្វើការលើសពី២ឆ្នាំ) និងផ្ទេរសិទ្ធិឱ្យសហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជាធ្វើជាតំណាងចាប់ពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។

៣- សារណាដំណើររឿងវិវាទនៅក្រុមហ៊ុន ខេមប្រ៊ូវ។

៤- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុនផលិតស្រាបៀរអង្គរ លេខ ១២៣៤ កប/វក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧។

៥- លក្ខន្តិកៈសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុនផលិតស្រាបៀរអង្គរ ចុះបញ្ជិកាលេខ ១២៣៤ កប/វក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧។

៦- ស្នាមមេដៃរបស់បុគ្គលិកក្រុមហ៊ុនផលិតស្រាបៀរអង្គរ ចំនួន ៣៩ នាក់ ស្នើសុំឱ្យប្រធានសហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា ជាអ្នកតំណាង ដើម្បីដោះស្រាយជាមួយក្រុមហ៊ុននូវបញ្ហាវិវាទចំនួន៥ចំណុច។

៧- លិខិតលេខ ០១១/១១ សកចសក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ របស់សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា គោរពជូន នាយកក្រុមហ៊ុន ខេមប្រ៊ូវ សំណើសុំពិភាក្សាការងារស្តីពីលក្ខខណ្ឌការងារ សេរីភាពសហជីព សិទ្ធិ និងអត្ថប្រយោជន៍របស់កម្មករនិយោជិត។

៨- លិខិតលេខ ១៤១២/១០ សកចសក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ របស់សហព័ន្ធសហជីពកម្មករចំណីអាហារ និង សេវាកម្មកម្ពុជា គោរពជូន នាយកក្រុមហ៊ុន ខេមប្រ៊ូវ សំណើសុំពិភាក្សាការងារស្តីពីលក្ខខណ្ឌការងារ សេរីភាពសហជីព សិទ្ធិ និងអត្ថប្រយោជន៍របស់កម្មករនិយោជិត។

៩- កំណត់ហេតុដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេមប្រ៊ូវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេមប្រ៊ូវ លេខ ៥៤៧ ក.ប/អក/វ.ក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ខេមប្រ៊ូវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី១ លេខ ៣៦១ កប/អក/វក/លកអ. ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ៣៦២ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៣៦៥ កប/អក/វក/លកអ. ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១១។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៣៦៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១។

**អន្តហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ខេមប្រ៊ូវ គឺជាក្រុមហ៊ុនផលិត និងលក់ស្រាបៀរអង្គរ។ ក្រុមហ៊ុននេះ បានចាប់ដំណើរការនៅឆ្នាំ ២០០៩ ហើយបើតាមរបាយការណ៍មិនសះជា បច្ចុប្បន្ននេះ ក្រុមហ៊ុនមានជួលកម្មករនិយោជិត សរុបប្រហែលជា ១៥០០ នាក់។
- សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុនផលិតស្រាបៀរអង្គរ គឺជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។
- ភាគីនិយោជកបានដាក់បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ខេមប្រ៊ូវ ចុះបញ្ជិកាលេខ ០២៦ សកបយ.អក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ ជាភាសាបរទេស។ ផ្អែកតាមប្រការ ២៣ នៃប្រកាសលេខ ០៩៩ សកបយ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ "ភាសាដែលត្រូវប្រើក្នុងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺភាសាខ្មែរ ..."។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាឯកសារភស្តុតាង ដែលភាគីនិយោជកដាក់មកក្រៅពីភាសាខ្មែរនោះទេ។

**ចំណុចវិវាទទី១: ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់សំណងបន្ថែម ១០០ ភាគរយ សម្រាប់កម្មករនិយោជិត ដែលធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍គិតចាប់ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ ២០១០**

- ចាប់ពីខែមករា ឆ្នាំ២០១១មក ក្រុមហ៊ុនមិនអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកនៅចុងសប្តាហ៍ ទេ។
- នៅមុន ខែមករា ឆ្នាំ២០១១ ក្រុមហ៊ុនបានតម្រូវឱ្យកម្មករនិយោជិតទាំងអស់ធ្វើការរួមទាំងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ផង ពោល គឺធ្វើការ ៧ ថ្ងៃក្នុងមួយសប្តាហ៍ ហើយ ៨ ម៉ោងក្នុងមួយថ្ងៃ ដោយទទួល

បានប្រាក់ឈ្នួលចំនួន ៦០ ដុល្លារអាមេរិក ក្នុងមួយខែ។ ចំពោះកម្មករនិយោជិត ដែលធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ នឹងទទួលបានប្រាក់ឈ្នួលបន្ថែមចំនួន ២ ដុល្លារអាមេរិក។

- មានកម្មករនិយោជិត ចំនួន ៣៩ នាក់ ដែលបានផ្ទេរសិទ្ធិជូនសហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា ឱ្យធ្វើជាតំណាងក្នុងការទាមទារនេះ ចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ដោយ ធ្វើការទាមទារទៅនិយោជកឱ្យសងចំនួន ២ ដុល្លារអាមេរិកបន្ថែមទៀត ដោយគិតចាប់តាំងពីឆ្នាំ២០០៧ មកដល់ឆ្នាំ២០១០ ដល់កម្មករនិយោជិត ដែលបានធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍។
- នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ សហជីពបានដាក់ពាក្យសុំជួបចរចាទៅនិយោជក ប៉ុន្តែត្រូវនិយោជកបដិសេធពុំព្រមជួបចរចាទេ។
- នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១ ភាគីកម្មករនិយោជិតបានផ្តល់ជូនបញ្ជីឈ្មោះរបស់កម្មករនិយោជិតចំនួន ៣៩ នាក់ ដែលធ្វើការទាមទារ។
- នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ដែលជាថ្ងៃសវនាការ ភាគីនិយោជកបានជំទាស់នឹងឈ្មោះរបស់កម្មករនិយោជិតមួយចំនួននៅក្នុងបញ្ជីនោះ ដោយលើកឡើងថា ក្នុងចំណោមកម្មករនិយោជិតចំនួន ៣៩ នាក់នោះ មានកម្មករនិយោជិតខ្លះបានលាឈប់ហើយ ហើយកម្មករនិយោជិតខ្លះទៀតជាសមាជិករបស់សហជីពផ្សេង។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីកម្មករនិយោជិតត្រួតពិនិត្យឈ្មោះអ្នកទាមទារ និងដាក់បញ្ជីឈ្មោះរបស់កម្មករនិយោជិត ដែលធ្វើការទាមទារម្តងទៀត ត្រឹមថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១។
- តាមរយៈភស្តុតាង ដែលផ្តល់ដោយភាគីកម្មករនិយោជិត នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ នោះ មានកម្មការិនីចំនួន ៣៨ នាក់ ដែលបានផ្ទេរសិទ្ធិជូនសហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា ឱ្យធ្វើជាតំណាងក្នុងការទាមទារនេះ។
- ទន្ទឹមនឹងនេះដែរ ភាគីនិយោជកបានផ្តល់នូវភស្តុតាង ដែលបញ្ជាក់ថា មានកម្មករនិយោជិតចំនួន ១៦ នាក់ ដែលបដិសេធលើស្នាមផ្តិតមេដៃ ដែលពួកគាត់ធ្លាប់បានទាមទារកន្លងមក ពោលគឺពួកគាត់ពុំទាមទារទៀតទេ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្ទៀងផ្ទាត់លើឈ្មោះ ដែលផ្តល់ដោយភាគីកម្មករនិយោជិត និងនិយោជក ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញមានឈ្មោះកម្មករនិយោជិតចំនួន ៤ នាក់ ដូចគ្នាទៅនឹងឈ្មោះរបស់កម្មករនិយោជិត ដែលផ្តល់ដោយភាគីនិយោជក។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាតែលើកម្មករនិយោជិត ចំនួន ៣៤ នាក់ ប៉ុណ្ណោះ ដែលមានរាយនាមដូចខាងក្រោមនេះ:

THE ARBITRATION COUNCIL

| ល.រ | នាម-គោត្តនាម | អត្តលេខ | ល.រ | នាម-គោត្តនាម | អត្តលេខ |
|---|---|---|---|---|---|
| ១. | ឡុង រត្តណោ | ០២៧៨ | ១៨. | ឡុន ភាន | ០១៣៨ |
| ២. | សុង អារុណរះ | ០១៩១ | ១៩. | ហេង ផាន់នី | ០៣៧៥ |
| ៣. | ឃឿន សារ៉េត | ០៥៤៣ | ២០. | យឿង ស្រីមុំ | ០៦០៩ |
| ៤. | ស៊ីម ផាន | ០៥៣១ | ២១. | ឡុក វ៉ា | ០០៩៧ |
| ៥. | ទូច សុខលាង | ០០៥១ | ២២. | នុត ស្រស់ | ០២៣៩ |
| ៦. | អ៊ូ ចាន់ធឿន | ០៦១៣ | ២៣. | គត់ ចាន់ណា | ០១៩៦ |
| ៧. | អ៊ូ ចាន់ធូ | ០៤៤៨ | ២៤. | អៀង ធា | ០៥២៤ |
| ៨. | ពុជ ហឿន | ០២៦៧ | ២៥. | អ៊ុំ សុភក្រ្ត័ | ០៥៦៤ |
| ៩. | ពេជ្រ ស្រីមុំ | ០៤០១ | ២៦. | ដាំ ចំរុង | ០៥៣៤ |
| ១០. | ហ៊ី ធី | ០៦២៣ | ២៧. | វ៉ុត ស្រីនាង | ០៥៦៦ |
| ១១. | ណាល់ ពៅ | ០៣៥១ | ២៨. | ចាន់ថា ស្រីលក្ខ័ | ០៥៧០ |
| ១២. | សាន សុផាន | ០៥៦០ | ២៩. | លាក់ ភាព | ០២៣២ |
| ១៣. | លី អាន | ០២១១ | ៣០. | ស្វាយ សុផាត | ០៥៥៨ |
| ១៤. | សាយ ម៉េងស្រស់ | ០៦២៦ | ៣១. | ហេង ម៉ានី | ០៣៤៦ |
| ១៥. | សុខ លាង | ០៥៥៩ | ៣២. | អ៊ុត ស្រីអូន | ០៤៩៦ |
| ១៦. | ស៊ុំ ផារី | ០៦២៤ | ៣៣. | សេង ដានី | ០៤៣៥ |
| ១៧. | ស៊ីម ចាន់ធឿន | ០៥១៧ | ៣៤. | គង់ ស្រីណត់ | ០៥៨០ |

**ចំណុចវិវាទទី២: កម្មករនិយោជិតស្នើសុំឱ្យនិយោជកអនុវត្តកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ចំពោះកម្មករនិយោជិត ដែលធ្វើការចាប់ពី ២ ឆ្នាំ ឡើងទៅ**

- កម្មករនិយោជិត ដែលធ្វើការទាមទារនៅក្នុងសំណុំរឿងនេះ បានចាប់ផ្តើមចូលធ្វើការតាំងពីឆ្នាំ២០០០ មកម្ល៉េះ ដោយមានកិច្ចសន្យាការងារផ្ទាល់មាត់។ និយោជកពុំដែលធ្វើកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរជូនកម្មករនិយោជិតទេ។ ចាប់តាំងពីឆ្នាំ២០០៧មក ទើបនិយោជកចាប់ផ្តើមធ្វើកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ១ ឆ្នាំម្តងៗ មកដល់បច្ចុប្បន្ន។ រយៈពេលសរុបនៃកិច្ចសន្យាការងាររបស់កម្មករនិយោជិត ចាប់តាំងពីថ្ងៃចូលធ្វើការមកដល់បច្ចុប្បន្ននេះ គឺលើសពីពីរឆ្នាំ។
- កម្មករនិយោជិតបានលើកឡើងថា មូលហេតុនៃការទាមទារនេះ គឺដោយសារកម្មករនិយោជិតនឹងបាត់បង់អតីតភាពការងារ ហើយបើយោងតាមមាត្រា ៦៧ នៃច្បាប់ស្តីពីការងារ កិច្ចសន្យាការងាររបស់

កម្មករនិយោជិតទាំងអស់ជាកិច្ចសន្យាការងារ ដែលមានថិរវេលាមិនកំណត់។

**ហេតុផលនៃសេចក្តីសម្រេចៈ**

**ចំណុចវិវាទទី១: ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់សំណងបន្ថែម ១០០ ភាគរយសម្រាប់កម្មករនិយោជិត ដែលធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ គិតចាប់ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ ២០១០**

មាត្រា ១៣៧ នៃច្បាប់ស្តីពីការងារចែងថា *"គ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសល ព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ ថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវឱ្យលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងក្នុងមួយអាទិត្យឡើយ"*។

នៅក្នុងសំណុំរឿងលេខ ១១៤/០៨-វ៉ាយធិច ចំណុចវិវាទទី៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា *"តាមអត្ថន័យនៃមាត្រា ១៣៧ នៃច្បាប់ស្តីពីការងារខាងលើនេះ មានន័យថា ថិរវេលាធ្វើការធម្មតារបស់កម្មករនិយោជិតមិនត្រូវលើស ៨ ម៉ោងក្នុងមួយថ្ងៃ ឬ ៤៨ ម៉ោង ក្នុងមួយសប្តាហ៍ឡើយ។ ហេតុនេះហើយ កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ ដែលលើសពីថ្ងៃ និងម៉ោងធ្វើការធម្មតា គឺជាការងារបន្ថែមម៉ោង"*។

មាត្រា ១៣៩ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣៩ នៃច្បាប់ស្តីពីការងារចែងថា *"ក្នុងករណីមានកិច្ចការប្រញាប់ខុសធម្មតាតម្រូវឱ្យកម្មករនិយោជិត ធ្វើការបន្ថែមក្រៅម៉ោងពេលធម្មតាម៉ោងពេលបន្ថែមទាំងនេះ ត្រូវឱ្យឈ្នួលតាមអត្រាតម្លើង ៥០% (ហាសិបភាគរយ)។ ប្រសិនបើធ្វើការបន្ថែមនៅពេលយប់ ចន្លោះពីម៉ោង ២២ ទៅម៉ោង ៥ ភ្លឺ ឬនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវផ្តល់ប្រាក់បន្ថែមតាមអត្រាតម្លើង ១០០% (មួយរយភាគរយ)"*។

នៅក្នុងសំណុំរឿងលេខ ៩៦/១០-គ.ឈ ហ្សេស៊ិន ហេតុផលចំណុចវិវាទទី៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវផ្តល់ប្រាក់ឈ្នួលតាមអត្រាតម្លើង ១០០ ភាគរយ នៅពេលកម្មករនិយោជិតធ្វើការនៅថ្ងៃអាទិត្យ ដែលជាថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិតទទួលបានប្រាក់ឈ្នួលចំនួន ៦០ ដុល្លារអាមេរិកក្នុងមួយខែ ដោយប្រាក់នេះមិនរាប់បញ្ចូលថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ទេ។ ដូចនេះ នៅថ្ងៃដែលពួកគាត់មកធ្វើការ គឺពួកគាត់ទទួលបាន ២.៣ ដុល្លារអាមេរិកក្នុងមួយថ្ងៃសម្រាប់ថ្ងៃធ្វើការធម្មតា។ ដូច្នេះ បើយោងតាម ១៣៩ ថ្មី នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បើសិនជាកម្មករនិយោជិតធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ កម្មករនិយោជិតត្រូវទទួលបានប្រាក់បន្ថែមតាមអាត្រាតម្លើង ១០០ ភាគរយ មានន័យថា កម្មករនិយោជិតត្រូវទទួលបាន ៤.៦ ដុល្លារអាមេរិក។ តាមរយៈអង្គហេតុ និយោជកផ្តល់ជូនតែ ២ ដុល្លារ

អាមេរិកបន្ថែមតែប៉ុណ្ណោះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវផ្តល់ជូនកម្មករនិយោជិតចំនួន ២,៦ ដុល្លារអាមេរិកបន្ថែមទៀត។ ប៉ុន្តែ នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ចំនួន ២ ដុល្លារអាមេរិកបន្ថែម សម្រាប់ការធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ដោយមិនធ្វើការទាមទារ ០,៦ ដុល្លារអាមេរិកនោះទេ។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានទាមទារឱ្យនិយោជកសងប្រាក់នេះ ចាប់តាំងពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១០ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាទៅលើអាជ្ញាយុកាលនៃបណ្តឹងទាមទារនេះ ដូចតទៅ :

មាត្រា ១២០ កថាខណ្ឌ១ នៃច្បាប់ស្តីពីការងារបានចែងថា *"សិទ្ធិប្តឹងសុំបើកប្រាក់ឈ្នួលត្រូវផុតរលត់រយៈពេលបីឆ្នាំ ក្រោយពីថ្ងៃកំណត់បើកប្រាក់ឈ្នួល"*។

យោងតាមមាត្រានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមានសិទ្ធិទាមទារឱ្យនិយោជកសងនូវប្រាក់ឈ្នួល ដែលនិយោជកបានបើកខ្វះនោះត្រឹមរយៈពេល ៣ ឆ្នាំ ប៉ុណ្ណោះ ក្រោយពីថ្ងៃបើកប្រាក់ឈ្នួល។

តាមរយៈអង្គហេតុ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ ភាគីកម្មករនិយោជិតបានដាក់បណ្តឹងទៅនិយោជកដើម្បីធ្វើការចរចា។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា អាជ្ញាយុកាលនៃបណ្តឹងរបស់ពួកគាត់មិនទាន់ផុតរលត់ទេ ពីព្រោះភាគីកម្មករនិយោជិតបានប្រើប្រាស់សិទ្ធិនេះនៅក្នុងរយៈពេល ៣ ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ រហូតដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០។

ដូចនេះ និយោជកត្រូវសងនូវប្រាក់ឈ្នួល២ដុល្លារអាមេរិកបន្ថែម តាមការទាមទាររបស់ភាគីកម្មករនិយោជិត ចាប់ពី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ រហូតដល់ ១៣ ខែធ្នូ ឆ្នាំ២០១០ សម្រាប់កម្មករនិយោជិត ចំនួន ៣៤ នាក់ ដែលមានឈ្មោះដូចខាងលើ។

**ចំណុចវិវាទទី២: កម្មករនិយោជិតស្នើសុំឱ្យនិយោជកអនុវត្តកិច្ចសន្យាការងារ ដែលមានថិរវេលាមិនកំណត់ចំពោះកម្មករនិយោជិត ដែលធ្វើការបានចាប់ពី ២ ឆ្នាំ ឡើងទៅ**

មាត្រា ៦៧ កថាខណ្ឌ ២ នៃច្បាប់ស្តីពីការងារចែងថា " *កិច្ចសន្យាការងារ ដែលធ្វើឡើងដោយការព្រមព្រៀងគ្នាដោយមានកំណត់ថិរវេលាពិតប្រាកដ មិនអាចមានរយៈពេលលើសពីពីរឆ្នាំបានឡើយ។ កិច្ចសន្យានេះអាចបន្តសាជាថ្មីម្តង ឬច្រើនដងបាន ដរាបណាការបន្តសាជាថ្មីនោះមានថិរវេលាអតិបរមាមិនលើសពីពីរឆ្នាំ។*

*ការអនុវត្តផ្ទុយនឹងវិធានខាងដើម នាំឱ្យកិច្ចសន្យាការងារនោះ ក្លាយជាកិច្ចសន្យាដែលគ្មានកំណត់ថិរវេលាពិតប្រាកដ* "។

មាត្រា ៧៣ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីការងារចែងថា " *ប្រសិនបើកិច្ចសន្យាមានកំណត់ថិរវេលាលើសពី ៦ ខែ កម្មករនិយោជិតត្រូវបានគេជូនដំណឹងមុនចំនួន ១០ ថ្ងៃ អំពីការផុតរលត់នៃកិច្ចសន្យា ឬការមិនបន្តឡើងវិញនៃកិច្ចសន្យា។ រយៈពេលជូនដំណឹងមុននេះ ត្រូវកំណត់ឱ្យដល់ ១៥ ថ្ងៃ ចំពោះកិច្ចសន្យាមានថិរវេលាលើសពី១ឆ្នាំ។ បើគ្មានការជូនដំណឹងមុនទេ កិច្ចសន្យាត្រូវបន្តក្នុងថិរវេលាស្មើគ្នានឹងថិរវេលា ដែលបានចុះកិច្ចសន្យាគ្រាដំបូង ឬត្រូវចាត់ទុកថា ជាកិច្ចសន្យាគ្មានកំណត់ថិរវេលាពិតប្រាកដ បើថិរវេលាសរុបនៃការបន្តកិច្ចសន្យានោះលើសពីថិរវេលាដែលមានកំណត់ក្នុងមាត្រា៦៧* "។

នៅក្នុងសេចក្តីបង្គាប់លេខ ១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលចំណុចវិវាទទី ១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា " *ការបកស្រាយវាក្យខ័ណ្ឌ២ នៃមាត្រា៦៧ នៃច្បាប់ស្តីពីការងារនេះ មានន័យថា កិច្ចសន្យាមានថិរវេលាកំណត់ ត្រូវក្លាយជាកិច្ចសន្យាមានថិរវេលាមិនកំណត់កាលណាការបន្តជាថ្មីនៃកិច្ចសន្យានេះ នាំឱ្យថិរវេលាសរុបនៃកិច្ចសន្យាការងារដំបូង និងថិរវេលានៃកិច្ចសន្យាបន្តលើសពី២ឆ្នាំ* "។ (សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *លេខ ៣៦/០៦ - ម៉ុនដូតិច្ស ហេតុផលចំណុចវិវាទទី២ និងលេខ ៥៧/០៦-អេវើគ្រីន ហ្គាមិន ហេតុផលចំណុចវិវាទទី៣*) ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកប្តូរកិច្ចសន្យាការងារមានថិរវេលាកំណត់ទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ដោយសារការអនុវត្តកិច្ចសន្យាមានថិរវេលាកំណត់របស់ក្រុមហ៊ុនបានបន្តកិច្ចសន្យានោះលើសពី ២ ឆ្នាំ ដែលផ្ទុយនឹងខ្លឹមសារនៃមាត្រា ៦៧ នៃច្បាប់ស្តីពីការងារ ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលសំណុំរឿងលេខ *១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលចំណុចវិវាទទី១, លេខ ៣៦/០៦-ម៉ុនដូតិច្ស ហេតុផលចំណុចវិវាទទី២ និងលេខ ៤០/១១-*យ៉ាង តិង *ហេតុផលចំណុចវិវាទទី៦* ) ។

តាមរយៈអង្គហេតុ កម្មករនិយោជិតចំនួន ៣៤ នាក់ បានចូលធ្វើចាប់តាំងពីឆ្នាំ២០០០ មក ដូចនេះថិរវេលានៃកិច្ចសន្យាការងាររបស់ពួកគាត់លើសពីពីរឆ្នាំ។ យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ៣៤ នាក់ខាងលើ គឺជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ថ្វីត្បិតតែនិយោជកបានចាប់ផ្តើមធ្វើកិច្ចសន្យាការងារ ដែលមានថិរវេលាកំណត់រយៈពេលមួយឆ្នាំចាប់តាំងពីឆ្នាំ២០០៧ក៏ដោយ គឺកិច្ចសន្យាទាំងនោះ នឹងក្លាយទៅជាកិច្ចសន្យាការងារ ដែលមានថិរវេលាមិនកំណត់បើរយៈពេលសរុបរបស់វាលើសពីពីរឆ្នាំ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចឱ្យនិយោជកប្តូរកិច្ចសន្យាការងារកម្មករនិយោជិតទាំង ៣៤ នាក់ ដែលមានថិរវេលាសរុបនៃកិច្ចសន្យាការងារលើសពី ២ ឆ្នាំ ទៅជាកិច្ចសន្យា ដែលមានថិរវេលាមិនកំណត់។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ :

# សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ :**

បង្គាប់ឱ្យនិយោជកសងប្រាក់ឈ្នួលចំនួន ២ ដុល្លារអាមេរិកបន្ថែម ចាប់ពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ រហូតដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ សម្រាប់កម្មករនិយោជិតទាំង៣៤នាក់ ដែលធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍។

**ចំណុចវិវាទទី ២ :**

បង្គាប់ឱ្យនិយោជកប្តូរកិច្ចសន្យាការងារកម្មករនិយោជិតទាំង ៣៤ នាក់ ដែលមានថិរវេលាសរុបនៃកិច្ចសន្យាការងារលើសពី ២ ឆ្នាំ ទៅជាកិច្ចសន្យា ដែលមានថិរវេលាមិនកំណត់។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **យូ សួននី**

ហត្ថលេខា: ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **អន ណន**

ហត្ថលេខា: ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **អាំង អេងថុង**

ហត្ថលេខា: ------------------------------